ហិង្សា ឬ អហិង្សា ?

សេរីការ

នៅក្នុង បរិបទខ្មែរបច្ចុប្បន្ន កត្តាពេលវេលា ជា អត្ថសញ្ញាសំខាន់ណាស់សំរាប់ជីវិត នៃប្រជាជាតិខ្មែរ ព្រោះស្រុកខ្មែរសព្វថ្ងៃ កំពុងប្រឈរមុខនឹង បញ្ហាអន្តោប្រវេសន៍ នៃជាតិសាសន៍យួនរាប់លាននាក់ ចូលមកក្នុងស្រុកខ្មែរ គ្មានបញ្ចប់។ អន្តោប្រវេសន៍ នេះជា នយោបាយរៀបចំច្បាស់លាស់របស់រដ្ឋាភិបាលយៀកណាម ក្នុងគោលបំណង ត្រួតត្រាស្រុកខ្មែរ ដោយយកចំនួន ជនយួនខ្នាន់ខ្នាប់រស់នៅពាសពេញស្រុកខ្មែរ សំរាប់រាតដី ដែល គេអោយឈ្មោះថា នយោបាយ អាណានិគម នៃប្រជាភិវឌ្ឍន៍។ បច្ចុប្បន្ននេះ ជនជាតិយួន រស់នៅស្រុកខ្មែរ មានចំនួនគ្រប់គ្រាន់ សំរាប់ ពួកគេ ពោលអះអាង នៃអត្ថភាព ជាកកវ័ត (puissant) របស់និគមជនយួន នៅក្នុងសង្គមខ្មែរ។ រយៈពេលតែ ៣៧ ឆ្នាំ (១៩៧៩-២០១៦) តែប៉ុណ្ណោះ ស្រុកយួន ក្លាយជា ប្រទេសអធិរាជនៅតណ្ឌចិន ដែលមាន ស្រុកខ្មែរ និង លាវ ជា ប្រទេសរណប។ ពិតមែនតែ អ្នកដឹកនាំយួនគ្រប់ជំនាន់តែងតែមាន មហិច្ឆាតាខ្ជាប់ខ្ជួនរយឆ្នាំ តែនៅក្នុង បីទសវត្សរ៍ក្រោយនេះ ពួកគេទុកលទ្ធផលសព្វថ្ងៃ ជាអបុព្វកិច្ច (exploit) លើសពីការគិតស្មាន របស់គេទៅទៀត ជាពិសេស ទោះជាមានកិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ១៩៩១ ជាខែលសំរាប់ការពារស្រុកខ្មែរ តែខែលនេះបែរជាក្លាយជាឧបករណ៍ សំរាប់

ការពារពួកគេទៅវិញ។ ត្រូវខ្មែរយើងមានស្គារតីថា អ្វីដែលអ្នកដឹកនាំយួន គេចង់បាន មកដល់សព្វថ្ងៃនេះ វាសមិទ្ធិកម្ម ចប់សព្វគ្រប់អស់ហើយ ព្រោះដំណើរ នៃការបែកខ្ទេចសង្គមខ្មែរ ពុំអាចបញ្ឈប់បាននោះឡើយ។ គំនិតនេះមិនមែន ជាគំនិតទុទ្ធិនិយមនោះឡើយ បើខ្មែរយើងស្គាល់ខ្លួនឯងច្បាស់ ហើយយល់ដឹងអំពីអកម្មភាព នៃជនជាតិខ្មែរនៅចំពោះមុខ បញ្ហាអាយុជីវិតជាតិខ្លួនព្រោះ ខ្មែរជាប្រជាពលរដ្ឋ រងទុក្ខអស់ច្រើនសតវត្ស ធ្វើអោយចុះទុនខ្សោយទាំងកម្លាំងកាយនិងប្រជ្ញា មិនអាចបន្តរក្សា អតីតកាលរុងរឿង របស់ជាតិខ្លួន និង ទទួលបន្ទុក ជាករណីយកិច្ច ការពារ ប្រជាជាតិខ្មែរបានទៀតនោះឡើយ។ តាំងពីសតវត្សទី១៥មក ស្តេចខ្មែរ ព្រះអង្គ តែងតែ ទៅពឹង កម្លាំងបរទេស ដើម្បីការពារអំណាច និង រាជាណាចក្រ ដែលនាំវិនាស ន្ទរបូរណភាពទឹកដីខ្មែរ។ ដើម្បី យល់ដឹង អំពីការបន្ត នៃអកុសលខ្មែរ រហូតមកដល់សព្វថ្ងៃនេះ បើយើកគ្រាន់តែយកភ្នែក សំរាប់មើលវានោះ មិនគ្រប់គ្រាន់នោះទេ ត្រូវយកវាមក គិតពិចារណា អំពីគំនិត ររើរាយ ថាខ្មែរយើងជាពួជមហានគរ តើជា គំនិតត្រឹមត្រូវដែរឬទេ នៅចំពោះមុខ ប្រជាជាតិខ្លួន បច្ចុប្បន្ន ដែលកំពុងរលំ ដូចជាភ្នំខ្សាច់ល្អុអស្ចារ្ស ? ភាពឡឹត អំនួត កំព្រើល អវិនិយ ខ្វះមនសិការ ខ្វះសំភី ខ្វះសេចក្ដីទៀងត្រង់ គ្មានប្រជ្ញា អសម្ភភាពដោះស្រាយពហុបញ្ហា គ្មានគោលវិធីច្បាស់លាស់ កញ្ជ្រោត របស់អ្នកដឹងនាំជាតិនិងអ្នកនយោបាយខ្មែរ ក្នុងរយៈពេល បីទសវត្សរ៍ចុងក្រោយនេះ

ជាលាភជ័យ ដល់យួន សំរាប់ បំរើ នយោបាយ លេបទឹកដីខ្មែរ ប្រកបដោយប្រសិទ្ធិភាព។

គំនិតអហិង្សាអកម្ម

គំនិត អហិង្សា ដែល អ្នកដឹកនាំគណបក្សប្រឆាំង ឬ អ្នកប្រឆាំងមតិនឹង អំណាចយួន នៅស្រុកខ្មែរសព្វថ្ងៃនេះ យកមកធ្វើជាគោលនយោបាយ គឺជា ការបញ្ជាក់ នូវ និស្សកម្ម (inaction) នៃជនជាតិខ្មែរនៅចំពោះមុខ ហានិភ័យជាតិនោះឯង។ ដូច្នេះ គំនិត របស់អ្នកដឹកនាំគណបក្សប្រឆាំង គ្រាន់តែជាពន្លឺនួះ របស់គំនិតទូទៅ នៃជនានុជនខ្មែរយើង តែប៉ុណ្ណោះ។ គំនិត អហិង្សា ដែលខ្មែរយើង កំពុងនាំគ្នា យកមកធ្វើជាមធ្យោបាយ សន្តិវិធី សំរាប់ដោះស្រាយ បញ្ហាអាយុជីវិត ប្រជាជាតិខ្មែរ វា ជា សញ្ជាត (existence naturelle) ដែលមាននៅក្នុង អារម្មណ៍បារម្ភ ខ្មែរ ច្រើនសតវត្សមកហើយ នៅចំពោះមុខ សម្ពាធចិត្ត នៃ អ្នកដឹកនាំ យួន/សៀម មកលើប្រជាជាតិខ្មែរ។ គំនិតអហិង្សា បែបនេះ មិនមែនជា អាវុធការពារជាតិនោះឡើយ ព្រោះវាជា អហិង្សាអកម្ម គ្មាន ថាមពល អាចបង្កើតបានជា កម្លាំង ទប់ទល់ក្តី កម្លាំង វាយប្រហារក្តី សំរាប់ប្រឈរមុខនឹង សត្រូវ របស់ប្រជាជាតិខ្មែរ។ ដូចជាទស្សនៈខ្មែរមួយ ថា « ស្លូតស្លាប់ » គឺជាទស្សនៈចង់បង្ហាញអំពី គុណវិបត្តិ នៃគំនិតអហិង្សា បើ យកវា មកប្រើគ្រាន់តែចង់បង្ហាញនូវទឹកចិត្តស្លូតបូត ជាអ្នក មានធម៌ តែប៉ុណ្ណោះ។ គេអាចសួរជាសំនួរថា អ្វីទៅជាគំនិត អហិង្សាសកម្ម ?

គំនិតអហិង្សសកម្ម

ជាសិទ្ធិការពារខ្លួន តាមមធ្យោបាយ ដែលអ្នកទទួលរងគ្រោះ យកវាមកប្រើ ដើម្បី ការពារខ្លួន ដូចជា មធ្យោបាយច្បាប់ បាតុកម្មស្របច្បាប់ក្តី មិនស្របច្បាប់ក្តី សង្គ្រាមការពារជាតិ ដែល យើងរមែងគិតថា សុទ្ធជាអំពើហិង្សា។ អំពើហិង្សាបែបនេះ គឺត្រូវធ្វើ នៅក្នុងគំនិតអហិង្សា ដែលយើងអោយឈ្មោះថា គំនិតអហិង្សាសកម្ម ព្រោះជាប្រតិកម្មប្រឆាំងនឹង អយុត្តិធម៌ ដែលមានច្បាប់ជាអ្នកធានាការពារ។ ទោះបី នៅស្រុកខ្មែរសព្វថ្ងៃជា ប្រទេសនៅក្រោមអាណានិគមយួនក៏ដោយ តែខ្មែរមានច្បាប់ សំរាប់ ការពារសិទ្ធិ របស់ ពលរដ្ឋ បូរណភាពទឹកដី និង អធិបតេយ្យភាពជាតិ ព្រោះខ្មែរមាន កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា១៩៩១ ជាកូនសោ សំរាប់ដោះស្រាយគ្រប់បញ្ហាជាតិ និង អាចរំដោះស្រុកខ្មែរ ពីអាណានិគមយួន បើប្រជាពលរដ្ឋ ខ្មែរមាន ឆន្ទៈពិតប្រាកដ និង មាន អ្នកដឹកនាំ ចលនារំដោះ ជាតិមាន សមត្ថចិត្ត ធ្វើពលកម្មគ្រប់បែបយ៉ាងដើម្បីជាតិ។ ចលនារំដោះជាតិ មិនចាំបាច់មាន លក្ខណៈជា ចលនាលួចលាក់នោះទេ ព្រោះ ស្រុកខ្មែរមានច្បាប់ តែច្បាប់ខ្មែរសព្វថ្ងៃ ត្រូវអាណានិគមយួន នៅស្រុកខ្មែរ គេបំពាន ដូច្នេះខ្មែរយើង ក្រាន់តែយកច្បាប់ ដែលមាននោះមកអនុវត្តអោយទៀងទាត់ ជាសកម្មភាព អហិង្សាសកម្ម ដែល ច្បាប់ អនុញ្ញាតអោយធ្វើ។ មិនត្រូវនាំគ្នាឈរចាំឃ្លាំមើល អាជ្ញាធរយួន បំពានច្បាប់ខ្មែរឬ ដេកចាំ ពួកខ្មែររណបយួន ស្មើ នូវដំណោះស្រាយមួយ ដែលពួក

គេចង់បាន ដូចពួក អ្នកដឹងនាំគណបក្សប្រឆាំង កំពុងនាំគ្នាដេកសង្ឃឹមថា អាចនឹងមានដំណោះស្រាយជាមួយ គណបក្សកាន់អំណាច ព្រោះការទាមទាររបស់ខ្លួនវាមានកំរិតទាប គឺសុំអោយតែស្ថានភាពនយោបាយ ក្រឡប់មករក ភាពប្រក្រតីឡើងវិញ តែប៉ុណ្ណោះ៖ សួរថាតើភាពប្រក្រតី ដែលពួកគាត់ចង់បាននោះជាអ្វីពិត ? គឺថា គណបក្សកាន់អំណាច គេចង់ធ្វើអ្វីក៏ធ្វើទៅ កុំអោយតែប៉ះពាល់ដល់បុព្វសិទ្ធិ និង អត្ថប្រយោជន៍ជាវត្ថុ របស់ពួកខ្លួន ក្នុងហាន:ជាឯកឧត្តម និង ជំទាវ (ចូលស្តាប់ ពួកអ្នកដឹងនាំគណបក្សប្រឆាំង ដែលតាំងខ្លួនជាអ្នកបំរើរាស្ត្រ គាត់ប្រើពាក្យ ឯកឧត្តម និង ជំទាវ ជានិច្ច សំរាប់ហៅរួសមាត់ ក្នាគាត់ទៅវិញទៅមកគ្មានការអៀនខ្មាស់នោះឡើយ។ សួរថា តើក្នុងកំនិតជម្រៅ របស់ពួកគាត់ វាមានខុសគ្នាត្រង់ណានឹង ពួកឯកឧត្តមនិងជំទាវរបស់គណបក្សកាន់អំណាច ?)

សេចក្ដីសន្និដ្ឋាន

អំពើអហិង្សា ក្នុង កំនិតកំសាក នៅចំពោះមុខអំពើអយុត្តិធម៌ មិនអាចទុកជា គុណសម្បត្តិបាននោះឡើយ ព្រោះវាជាទំនាស់ នៃធម្មជាតិមនុស្សលោក ដែលជា សត្វលោក មានបញ្ញា ជាអត្ថអំណាច សំរាប់តស៊ូប្រឆាំងនឹង អំពើអយុត្តិធម៌។ អត្ថអំណាចនេះឯង ជាអំណាច នៃមនុស្សលោក ដែលជាកម្លាំងដើរទៅរក ការរីកចំរើន នៃសីលធម៌ នៃមនុស្សជាតិ។ ដូច្នេះបានជា អំពើអហិង្សាក្នុងកំនិតកំសាក វានៅមានតិចតួចបំផុត នៅក្នុងលោកនេះ បើប្រៀបធៀបនឹងការលូតលាស់

នៃការចេះដឹង របស់មនុស្សលោក ក្នុងវិស័យ សិទ្ធិមនុស្ស និង ពលរដ្ឋ។ នៅចំពោះមុខ ក្រាប់អំពើអយុត្តិធម៌និងអាណានិគម ឃ្លានបើខ្មែរយើង ប្រព្រឹត្ត អំពើអហិង្សាកំសាក គឺនាំគ្នាសម្ងំរស់ យកតែសុខអាត្មារៀងៗខ្លួន ឬ ដេកចាំ មេត្តាឃ្លាន ដូចគណ បក្សប្រឆាំងបច្ចុប្បន្ន។ សេចក្ដីសុខនេះ គឺ ខ្មែរយើង កំពុងដើរ បញ្ច្រាស ផ្ទុយពីដំណើរ នៃមនុស្សជាតិហើយ។ ខ្មែរយើងពិតជា កំពុងនាំគ្នាដើរ មួយជំហានម្តងៗ តែជាជំហាន ក្រឡប់ថយ ក្រោយ។ កុំនាំគ្នា យកជាតិសាសន៍ខ្មែរទៅប្រដូចនឹង ជាតិសា សន៍ដទៃទៀត ដែលកំពុងរស់នៅ ក្នុងភាពពិបាកជាងខ្មែរទៅ ទៀត ដើម្បីលួងចិត្តខ្លួនឯង ព្រោះការប្រៀបធៀបនេះ វាផ្ទុយ នឹង អារម្មណ៍របស់ខ្មែរយើង ដែលតែងតែទុកខ្លួនជាពូជមហា នគរ។ បើចេះតែយកអ្វី ដែលជាភាពអន់ មកប្រដូចនឹងខ្មែរ យើង គឺយើងនាំគ្នាឈប់និយាយថា ប្រជាជាតិខ្មែរ មានអារ្យធ ម៌ថ្នំ់ថ្កើង និង មានវប្បធម៌ខ្ពង់ខ្ពស់ទៀតទៅ ព្រោះភាពអន់ វា មិនស្ទើនឹង សំដីអ្នកអាងនោះឡើយ។ អ្នកដឹងនាំជាតិនិមួយៗ គេតែមានអំនួតអ្នកពីជាតិរបស់គេ រីឯអ្នកដឹកនាំជាតិខ្មែរ វិញ បើអ្នកគឺ យកតែរបបខ្មែរក្រហម មកប្រៀបធៀបថា ការ ដឹកនាំ របស់ខ្លួនវាល្អជាងរបបខ្មែរក្រហម ព្រោះ មានការរីកចំ រើន នៅក្នុងសន្ដិភាពមួយ ដែលជាស្នាដៃរបស់ពួកអ្នកដឹកនាំ បច្ចុប្បន្ន ដូច្នេះបើមាន ការដូរអ្នកដឹកនាំ នឹងមានកើតសង្គ្រា ម។ ត្រូវខ្មែរយើងមាន ស្មារតីថា បើយើងខ្លាចការកំរាមនេះគឺ ធ្លាស់ជាយើងជ្រើសយក អំពើអហិង្សាកំសាក អហិង្សាអកម្មសំ រាប់រស់បានសុខជា ជនខ្មែរ តែមិនពិតជាមាន កិត្ដិយសជា

ពលរដ្ឋខ្មែរនោះឡើយ ព្រោះរស់បែបនេះជា ពេលវេលាជាឃាតការ សំរាប់ប្រជាជាតិខ្មែរ នៅចំពោះមុខប្រទេសជិតខាងយើងដែលគេ អនុវត្តនយបាយណ្ណានពានគ្រប់រូបភាព មកលើប្រជាជាតិខ្មែរ។ មានតែអំពើអហិង្សាសកម្ម ឬ ហិង្សាស្រេបច្បាប់ទេដែលអាច រំដោះប្រជាជាតិខ្មែរ ពីអាណានិគមយួនបាន។ បើនាំគ្នា អង្គុយចាំតែបោះឆ្នោត នៅក្នុងរបបអាណានិគម ឬ សង្ស៊ីមលើ រំឬជម៌សន្ទនា គ្មានគោលការណ៍ពិតប្រាកដហើយ គិតតែពីសូត្ររួសមាត់ថា « ដំណើរទៅរកការបោះឆ្នោត » គឺ យើងនាំគ្នារស់ នៅក្នុងអឬបញ្ហារួម នោះឯង។ ទោះបីពួកអ្នកដឹងនាំគណបក្សប្រឆាំង ខំសូត្រជា ទ្រឹស្តីថាដំណើរ ទៅរកការបោះឆ្នោត មានការពិចារណា លើកម្មវិធីច្បាស់លាស់ ជា តំណាក់ការ មុន-ពេល-ក្រោយ ការបោះឆ្នោត គឺជា ការបោកបញ្ជោត ប្រជាពលរដ្ឋ ដោយយក ទ្រឹស្តីឧបទេស មកយោសនាសូត្ររួសមាត់ ព្រោះសកម្មភាព វាគ្មាន កំជាប់នឹង បរិបទ នៃជីវិតភាពនយោបាយខ្មែរ បន្ទិចសោះឡើយ។ ដូចថ្មីៗនេះ ពួកអ្នកដឹកនាំគណបក្សប្រឆាំង គាត់នាំគ្នាអបអរសាទរ គ្រាន់តែឮថា គ.ជ.ប. ប្រកាសជ្រើសរើសបុគ្គលិក ហើយទុកការប្រកាសនេះជា អំពើវិជ្ជមាន ដោយមិនរវល់គិតអំពី ហានភាគី (en état de péril) នៃ គ.ជ.ប. បច្ចុប្បន្ន ដែល មិនអាចនឹងក្លាយជាអង្គការ អាព្យាក្រឹត សំរាប់ធានា ការបោះឆ្នោត នៅ ឆ្នាំ២០១៧-១៨ ១មាន ភាពត្រឹមត្រូវ បាននោះឡើយ។ យើងមើលឃើញថា គំនិត អបអរសាទរនេះ វាអត្តខាត់ណាស់ សំរាប់អ្នកដែលតាំងខ្លួនជា ឃ្លីតដ៏ចំណាន (grand penseur) ដែល វាគ្មានកំពស់ ស្មើនឹង

គុណប្រយោជន៍ (enjeu) សំរាប់ជាតិ៖ កុំឃើញយួន ធ្វើស្រោមដាវ នាំគ្នាសោមនស្ស ថាយួន លែងយកដាវកាប់ខ្មែរ ហើយ នាំគ្នាលួងខ្មែរ អោយខ្មែរអោបដៃ មើលយួនចូលស្រុកតាមសេរី ហើយ ត្រូវខ្មែរ មានជំនឿ លើ រឫទ្ធិ៍ សន្ទនាថាជា ដំណោះស្រាយ ដ៏ល្អបំផុត សំរាប់ជាតិ (មកដល់សព្វថ្ងៃនេះ រឫទ្ធិ៍ សន្ទនានេះ មិនដែលបង្ហាញនូវ ភាពវិជ្ជមានរបស់ខ្លួនសោះ)។ អំពើ អហិង្សា អកម្ម នៅចំពោះ មុខ នយោបាយ យួន គឺជាអំពើ អត្តឃាតកម្ម។ មានតែ ការ រួបរួម ខ្មែរ បង្កើតជាកម្លាំងជាតិ ទើប ខ្មែរ អាចរំដោះ ប្រជាជាតិ ខ្លួន ពីអាណានិគម យួនបាន តែ ការ រួបរួម នេះ ទៀត មិនមែន ដូចលោក សម រង្សី គាត់ចង់ បាន គឺ រួបរួម តែ ជាមួយ នឹ ងស្រមោលយួន គឺ លោក ហ៊ុន សែន ដែ ល ជាខ្មែ រ រ ង្វែ ងជាតិ ទុ ក ពាក្ យ « អ ាគ ុ ក » ថ ាជ ាពាក្ យ ร ป ส ่ ห ก ร ែ (អ ្ ห ก ร ែ ម ិ ន ថ ោ ห ដ ូ ច ห ា ร ย ล ់ ห ើ ញ ร ป ส ់ ล ោ ห ហ ុ ន ส ែ ห ន ោ ห ( ) ( ) ( )

តើមាន នរណាអាចប្រដៅ លោក ហ៊ុន សែន បាន ព្រោះគាត់ គ្រាន់តែជា ស្រមោលយួនប៉ុណ្ណោះ ដូច្នេះ ត្រូវខ្មែរយើងប្រដៅ យួនថា ខ្មែរជា ជាតិសាសន៍ មាន សីលធម៌ មាន សុជីវធម៌ មិន ដូច ស្រមោល របស់យួននោះឡើយដែលខ្លួនប្រើជាបាតដៃទី៣ លាក់ដៃយួន សំរាប់សម្លាប់ខ្មែរ តាមអំពើហិង្សា។ ចម្លើយមាន តែមួយ គឺត្រូវប្រើអំពើអហិង្សាសកម្ម ប្រឆាំងនឹង អំពើហិង្សា យួន នៅស្រុកខ្មែរ តាមច្បាប់ខ្មែរ។ អំពើនេះឯងហើយ ជា ពលិកម្មខ្មែរ ដែលជាតម្លៃ ដែលខ្មែរយើងត្រូវចំណាយ ជាញើស ជាឈាម នៃអ្នកស្នេហាជាតិ ដើម្បីឯករាជ្យជាតិខ្មែរសំរាប់ កសាង លិទ្ធិប្រជាធិបតេយ្យសេរី ជា យថាភូត។ ត្រូវមានស្មារតី ថា បញ្ហា នៅស្រុកខ្មែរសព្វថ្ងៃ ជា បញ្ហា ស្រុកខ្មែរ ជាមួយនឹង ស្រុកយួនជា បញ្ហាខ្មែរអ្នករងគ្រោះ ជាមួយនឹង យួនអ្នក ឈ្លានពាន ដូច្នេះកិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ១៩៩១ ជា ខសនៅ នៅមាន សុពលភាពជានិច្ច សំរាប់ប្រជាជាតិខ្មែរ។ អំពើហិង្សាក្តី អហិង្សាក្តី ដើម្បីការពារប្រយោជន៍ជាតិ ដែលខ្មែរ យកវាមកប្រើ នៅក្នុងក្របខណ្ឌ កិច្ចព្រមព្រៀងនេះ គឺជាការ ប្រើ ក្នុងស្មារតីជា អ្នកស្នេហាជាតិ ទុកជា អំពើមាន ធម្មានុរូប ឬ ស្របច្បាប់ និងប្រកបដោយ សីលធម៌ នៃមនុស្សជាតិ។